**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ក្រសួងបានបន្តខិតខំសម្របសម្រួលវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ស្របតាមតួនាទីដែលមានចែងក្នុងច្បាប់ជាធរមាន ក៏ដូចជាស្របតាមស្មារតីចង់បានរបស់តំណាងភាគីកម្មករនិយោជិតដែលចង់ជួបចរចាជាមួយក្រុមហ៊ុនផ្ទាល់ ដោយបានអញ្ជើញគូភាគីមកប្រជុំសម្របសម្រួលដោះស្រាយជាច្រើនលើកច្រើនសា ហើយនៅរសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នេះ ក្រសួងបានបន្តអញ្ជើញគូភាគីវិវាទមកជួបប្រជុំដោះស្រាយជាលើកទី៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម ទេស រុក្ខាផល អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ប. ដោយមានតំណាងភាគីកម្មករនិយោជិត រួមមាន លោកស្រី ឈឹម សុខន, លោកស្រី រី សុវណ្ណឌី, លោកស្រី សុន ស្រីពេជ្រ, លោកស្រី ហៃ សុភាព (អវត្តមានលោកស្រី ឈឹម ស៊ីថរ ដោយសារមានធុរៈចាំបាច់) និងតំណាងនិយោជក រួមមាន លោក Hein Dames, លោក ហាយ វលាភ, លោកស្រី ឌី ស៊ីហា និងលោកស្រី រស់ ប៊ុនឡេង ដោយភាគីទាំងពីរបានលើកឡើងនូវមតិយោបល់ ដូចខាងក្រោម៖

**មតិរបស់សហជីព និងតំណាងកម្មករនិយោជិត៖**

១. ថ្លែងអំណរគុណដល់ក្រសួង ដែលបានខិតខំស្វះស្វែងជួយអន្តរាគមន៍តាមផ្លូវច្បាប់ដើម្បីឱ្យតំណាងកម្មករនិយោជិតបាននៅក្រៅឃុំជាបណ្តោះអាសន្ន និងអាចចូលរួមប្រជុំដើម្បីដោះស្រាយវិវាទការងារនេះ។

២. នៅតែបន្តស្នើឱ្យលើកយកចំណុចទាមទារយកចូលធ្វើការវិញ មកពិភាក្សាមុននឹងឈានទៅពិភាក្សាចំណុចវិវាទផ្សេងទៀត ដោយស្នើឱ្យនិយោជកផ្តល់ចម្លើយតបចំពោះការទាមទារនេះ ហើយចំពោះកម្មករនិយោជិតដែលយល់ព្រមឈប់ពីការងារ សុំឱ្យមានការទូទាត់សំណងឱ្យបានត្រឹមត្រូវតាមច្បាប់។

៣. បានប្រគល់លិខិតស្នើសុំការដោះដូរកម្មករនិយោជិតតាមស្មារតីនៃកិច្ចប្រជុំថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ជូនភាគីក្រុមហ៊ុននៅក្នុងកិច្ចប្រជុំនេះផ្ទាល់តែម្តង និងបានចម្លងជូនក្រសួង នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ នេះ។

**មតិរបស់តំណាងក្រុមហ៊ុន ណាហ្គាវើលដ៍៖**

១. ថ្លែងអំណរគុណដល់ក្រសួង ដែលបានបន្តខិតខំរៀបចំឱ្យមានកិច្ចប្រជុំនេះ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

២. ក្រុមហ៊ុនបន្តបញ្ជាក់ជំហរថា ក្រុមហ៊ុនមិនអាចទទួលយកកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងាររួម ឱ្យចូលធ្វើការវិញបានទេ ហើយក៏មិនពិចារណាក្នុងការដោះដូរដូចដែលតំណាងកម្មករនិយោជិតបានស្នើសុំនោះដែរ ហេតុផលរបស់ក្រុមហ៊ុន គឺដូចបានបញ្ជាក់នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

៣. ក្រុមហ៊ុនបញ្ជាក់ដែរថា នៅក្នុងកិច្ចប្រជុំថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ក្រុមហ៊ុនបានព្យាយាមផ្តល់ហេតុផល និងពន្យល់នូវជំហររបស់ក្រុមហ៊ុនយ៉ាងក្បោះក្បាយ។ ប៉ុន្តែគួរឱ្យសោកស្តាយ ដែលជំហររបស់ក្រុមហ៊ុនត្រូវបានស្រង់ និងបកស្រាយខុស ដោយតំណាងកម្មករនិយោជិត នូវអត្ថន័យដើមរបស់ក្រុមហ៊ុននៅតាមបណ្តាញសង្គម ក៏ដូចជាសារព័ត៌មានដែលថា ក្រុមហ៊ុនមានគម្រោងកាត់បន្ថយកម្មករនិយោជិតចំនួន ៦០០នាក់បន្ថែមទៀត។ ចំណុចនេះ ក្រុមហ៊ុនបានបញ្ជាក់ថា មិនមែនជាការពិតទេ ព្រោះក្រុមហ៊ុនក៏មិនមានគម្រោងកាត់បន្ថយកម្មករនិយោជិតបន្ថែមទៀតទេ ទោះបីជាបច្ចុប្បន្នចំនួននេះលើសពីតម្រូវការក៏ដោយ ប៉ុន្តែក្រុមហ៊ុននៅតែរក្សាការងារជូនពួកគាត់ដដែល។

៤. ក្រុមហ៊ុននៅតែទទូចឱ្យមានការពិភាក្សាលើចំណុចផ្សេងទៀត ក្រៅពីចំណុចទី១ និងស្នើសុំឱ្យតំណាងកម្មករនិយោជិតមានភាពបត់បែន និងហេតុផលសមរម្យក្នុងការពិភាក្សាទៅលើចំណុចផ្សេងទៀត ដើម្បីឈានដល់ការព្រមព្រៀងណាមួយជាមួយក្រុមហ៊ុន ដែលវានឹងផ្តល់ប្រយោជន៍ដល់កម្មករនិយោជិតភាគច្រើន។

ក្រោយពីការពិភាក្សាគ្នាយ៉ាងផុសផុល ភាគីទាំងពីរបានឯកភាព ដូចខាងក្រោម៖

១. ភាគីទាំងពីរ នៅមិនទាន់ឈានដល់ចំណុចព្រមព្រៀងគ្នានៅឡើយទេ។

២. កំណត់កាលបរិច្ឆេទប្រជុំបន្ទាប់ នៅថ្ងៃអង្គារ ទី២៩ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទីរសៀល ដើម្បីឱ្យភាគីទាំងពីរ មានឱកាសពិចារណាឡើងវិញ អំពីលទ្ធភាពនៃការសម្បទានគ្នាទៅវិញទៅមក ដែលអាចឈានទៅបញ្ចប់វិវាទនេះ។

ក្រសួងសូមបញ្ជាក់សាជាថ្មីម្តងទៀតថា បើទោះបីជាមិនទាន់មានការឯកភាពគ្នា ក៏ក្រសួង នឹងបន្តខិតខំធ្វើការសម្របសម្រួល និងកំណត់កាលបរិច្ឆេទប្រជុំបន្តបន្ទាប់ទៀត ស្របតាមតួនាទីដែលកំណត់ដោយច្បាប់ ក៏ដូចជាការទាមទាររបស់គូភាគី។

ជាថ្មីម្តងទៀត ក្រសួងស្នើឱ្យភាគីទាំងពីរមានការយោគយល់គ្នាខ្ពស់ក្នុងការចូលរួមដោះស្រាយបញ្ចប់វិវាទការងារនេះ, បន្តសហការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធដោយសន្តិវិធី, និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ យោងតាមនីតិវិធីច្បាប់ ប្រសិនបើវិវាទការងារនេះមិនអាចស្វែងរកដំណោះស្រាយបានដោយការផ្សះផ្សា នីតិវិធីបន្ទាប់គឺអាចបញ្ជូនទៅតុលាការ ដើម្បីរកដំណោះស្រាយចុងក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២